# ដំណើរការជ្រើសរើសក្រុមពិគ្រោះយោបល់ដោយខ្លួនឯង

ចំណុចទី ១៖ តើអ្នកណាខ្លះមានលក្ខណៈសម្បត្តិដើម្បីចូលរួមបោះឆ្នោត?

អ្នកដែលមានលក្ខណៈសម្បត្តិដើម្បីបោះឆ្នោតគួរតែជាអង្គការនានាដែលមានមូលដ្ឋាននៅកម្ពុជា តែមិនមែនជាបុគ្គលទេ។ អង្គការនីមួយៗមានសិទ្ធិបោះឆ្នោតតែម្តងគត់ (ដោយហេតុថា ក្រុមអ្នកពាក់ព័ន្ធនីមួយៗត្រូវបោះឆ្នោតជ្រើសរើសតំណាងចំនួនពីររូប ដែលតំណាងម្នាក់ៗទាំងនេះត្រូវមានសម្លេងឆ្នោតចំនួនពីរ ប៉ុន្តែអង្គការនីមួយៗអាចធ្វើបែបនេះបានតែម្តងគត់ ពោលគឺ អ្នកមិនអាចមនុស្សច្រើននាក់មកពីអង្គការតែមួយចូលរួមនៅក្នុងការបោះឆ្នោតឡើយ)។

ចំណុចទី២៖ បញ្ជីឈ្មោះអ្នកបោះឆ្នោត

ត្រូវមានបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលរៀបចំឡើងសម្រាប់ក្រុមអ្នកពាក់ព័ន្ធនីមួយៗ។ សម្រាប់សហគមន៍ព្រៃឈើ/សហគមន៍តំបន់ការពារធម្មជាតិ/សហគមន៍នេសាទ ការធ្វើបែបនេះអាចជាដំណើរការងាយមួយ ដោយសារមានក្រុមបែបនេះ ក្នុងចំនួនកំណត់តែប៉ុណ្ណោះនៅកម្ពុជា ដូច្នេះលក្ខណៈសម្បត្តិគឺជាអ្វីដែលបង្ហាញច្បាស់។ ចំពោះអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិតារាងបែបនេះក៏ប្រហែលជាអាចបង្ហាញច្បាស់ផងដែរ។ ចំពោះអង្គការមិនមែនរដ្ឋាភិបាលជាតិ គ្រឹះស្ថានសិក្សា និងវិស័យឯកជនតារាងឈ្មោះនេះមិនសូវច្បាស់លាស់ទេ ដោយសារមានអង្គការបែបនេះជាចំនួនច្រើន ហើយការកំណត់ថាតើអង្គការណាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងដែលត្រូវតែចូលរួម មិនអាចបង្ហាញច្បាស់លាស់ទេ។ ដើម្បីជៀសវាងការរំខានណាមួយពីរដ្ឋាភិបាល គេត្រូវតែយល់ច្បាស់ថា ការសម្រេចអំពីលក្ខណៈសម្បត្តិ ត្រូវតែឆ្លុះបញ្ចាំងពីលក្ខណៈសម្បត្តិរបស់សមាជិករបស់ VFC ផងដែរ (សមាជិកមកពីអង្គការមិនមែនរដ្ឋាភិបាលជាតិ គ្រឹះស្ថានសិក្សា និងវិស័យឯកជន)។ ដំណើរការជ្រើសរើសក្រុមជនជាតិដើមភាគតិចត្រូវបានកំណត់រួចជាស្រេចមកហើយ។

ចំណុច ៣៖ ដំណើរការបោះឆ្នោត

គោលគំនិតដំបូងគឺការបោះឆ្នោតត្រូវធ្វើឡើងនៅក្នុងសិក្ខាសាលាជ្រើសរើសថ្នាក់ជាតិ ដែលលើកស្នើពីថ្ងៃ ២៨-២៩ ខែសីហា ហើយកិច្ចការនេះគួរតែបន្ត តាមរយៈការបោះឆ្នោតជាសម្ងាត់។

ដើម្បីផ្តល់ភាពបត់បែនបានសម្រាប់ការបោះឆ្នោត VFC បានលើកស្នើឲ្យប្រើប្រាស់ដំណើរការតាមប្រព័ន្ធអេឡិចត្រូនិកដោយអាចប្រើប្រាស់កញ្ចប់កម្មវិធីអង្កេត Monkey package។ ដើម្បីជៀសវាងការចោទប្រកាន់អំពីភាពលំអៀងណាមួយទៅអនាគត ការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិកនឹងធ្វើឡើងសម្រាប់ក្រុមអ្នកពាក់ព័ន្ធទាំង ៨ សូម្បីតែយើងសង្ស័យថា យ៉ាងហោចណាស់សម្រាប់ក្រុមអ្នកពាក់ព័ន្ធចំនួន ៤ (សហគមន៍ព្រៃឈើ/សហគមន៍តំបន់ការពារធម្មជាតិ/សហគមន៍នេសាទ និងក្រុមជនជាតិដើមភាគតិច) ការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិកទំនងជាអាចប្រព្រឹត្តទៅបានក្នុងកម្រិតកំណត់តែប៉ុណ្ណោះ។

ដើម្បីកាត់បន្ថយហានិភ័យនៃការបន្លំក្នុងការបោះឆ្នោត និងដើម្បីរក្សាភាពសម្ងាត់នៃសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិក យើងលើកស្នើឲ្យមានដំណើរការដូចតទៅ៖

- អ្នកដែលមានសិទ្ធិបោះឆ្នោត ទទួលបានគន្លឹះអេឡិចត្រូនិក សម្រាប់ការអង្កេតក្រុមអ្នកពាក់ព័ន្ធរបស់ខ្លួន ដែលអាចភ្ជាប់ជាមួយនូវកូដសម្ងាត់ផងដែរ
- យ៉ាងហោចណាស់បុគ្គលិកអ.ស.ប អព្យាក្រឹត្យចំនួន ២ រូប ដែលមានមូលដ្ឋាននៅក្រុងបាងកក ពិនិត្យតាមដានការបោះឆ្នោត។ នៅពេលបោះឆ្នោត អ្នកបោះឆ្នោតត្រូវបញ្ជាក់ឈ្មោះអង្គការ និងឈ្មោះបុគ្គលដែលបោះឆ្នោត ក្នុងនាម អង្គការនោះ។ បើពុំនោះទេ សន្លឹកឆ្នោតនោះត្រូវចាត់ទុកថាមិនបានការ។
- អ.ស.បនៅបាងកក ពិនិត្យឈ្មោះអង្គការនោះ ធៀបនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោត។
- ឧបមាថា អង្គការមួយមានឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជី អ.ស.បនៅបាងកក ឬ មន្ត្រីទំនាក់ទំនងពី CRTS ទាក់ទងជាមួយអង្គការនោះ ដើម្បីផ្ទៀងផ្ទាត់ថា បុគ្គលដែលបានបោះឆ្នោតគឺជាតំណាងពិតប្រាកដនៃអង្គការនោះ និងបានទទួលសិទ្ធិបោះឆ្នោតក្នុងនាមអង្គការនោះ។

- នៅចុងបញ្ចប់នៃអំឡុងពេលនៃការបោះឆ្នោត បុគ្គលិកអ.ស.បនៅបាងកក គណនាដោយឯករាជ្យអំពីចំនួនសម្លេងឆ្នោតបានការសម្រាប់បេក្ខជននីមួយៗ និង ផ្សព្វផ្សាយលទ្ធផល (ប៉ុន្តែមិនមែនអំពីសម្លេងឆ្នោតនីមួយៗទេ) ដល់មន្ត្រីទំនាក់ទំនងពី CRTS។ តាមរបៀបនេះ យើងអាចរក្សាបាននូវភាពសម្ងាត់នៃការបោះឆ្នោត។

យើងជឿថា ដោយសារតែអាចមានឧបសគ្គនានានៅក្នុងការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិក (ក្រុមខ្លះអាចមានកម្រិតកំណត់ក្នុងការប្រើប្រាស់) និងនៅក្នុងការមកបោះឆ្នោតដោយផ្ទាល់នៅក្នុងសិក្ខាសាលា (ការលំបាកក្នុងការធ្វើដំណើរមកភ្នំពេញ) ដូច្នេះយើងបានស្នើឲ្យមានជម្រើសទី៣។ ជម្រើសនេះគឺជាការបោះឆ្នោតតាមប្រៃសណីយ៍ - អ្នកបោះឆ្នោតគួរតែបានទទួលជម្រើសបញ្ជូនសន្លឹកឆ្នោតរបស់ខ្លួនតាមប្រៃសណីយ៍ ដែលត្រូវតែទទួលបានតាមកាលបរិច្ឆេទកំណត់ ដូចជា ៥ ថ្ងៃធ្វើការមុនថ្ងៃសិក្ខាសាលាជ្រើសរើសថ្នាក់ជាតិ។ ចំពោះការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវចាត់វិធានការនានាដើម្បីបញ្ចៀសកំហុសឆ្គង និងបញ្ចៀសការបោះឆ្នោតជាច្រើនលើក។ វិធានការទាំងនេះអាចដូចគ្នានឹងការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ លើកលែងតែដើម្បីកាត់បន្ថយថ្លៃចំណាយ ការបោះឆ្នោតតាមប្រៃសណីយ៍ អាចបញ្ជូនទៅការិយាល័យយូអ៊ីនឌីភីប្រចាំនៅកម្ពុជា ហើយបុគ្គលិកពីររូបនៅក្នុងការិយាល័យនេះនឹងធ្វើការពិនិត្យដំណើរការដូចគ្នានឹងការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការបោះឆ្នោតតាមប្រៃសណីយ៍ អាចជាជម្រើសតែក្នុងករណីណាដែលចំនួនបេក្ខជនមានច្រើនជាង២នាក់ សម្រាប់បណ្តាញសហគមន៍នីមួយៗ។ ដោយសារ បច្ចុប្បន្ននេះ មានបេក្ខជនតែ២ រូប ឬតិចជាងនេះសម្រាប់បណ្តាញសហគមន៍នីមួយៗ ការបោះឆ្នោតតាមប្រៃសណីយ៍ មិនជាការចាំបាច់ទេ។ លើសពីនេះ វាអាចជាការលំបាកបំផុត ក្នុងការចាត់ចែងការបោះឆ្នោតតាមប្រៃសណីយ៍ នៅក្នុងក្នុងរយៈពេលដែលនៅសល់។

ចំណុច ៤៖ ការរៀបចំសម្រាប់ការបោះឆ្នោត

អ្នកបោះឆ្នោតដែលមានលក្ខណៈសម្បត្តិសមស្របទាំងអស់គួរតែបានទទួលព័ត៌មានអំពីអាណត្តិ និងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមពិគ្រោះយោបល់ និងសេចក្តីពិពណ៌នាខ្លីៗអំពីប្រវត្តិរូបរបស់បេក្ខភាពសម្រាប់ក្រុមអ្នកពាក់ព័ន្ធរបស់ពួកគេ។ កិច្ចការនេះត្រូវបាន VFC គ្រោងទុករួចមកហើយ។

ព័ត៌មានបែបនេះគួរតែមាននៅក្នុងវេបសាយ REDD+ សម្រាប់កម្ពុជា និងគួរតែបានបញ្ជូនទៅអ្នកបោះឆ្នោតតាមអ៊ីម៉ែល។ នៅក្នុងករណីដែលអ្នកបោះឆ្នោតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ពុំមានអាសយដ្ឋានអ៊ីម៉ែល (ឬយើងមានហេតុផលដែលអាចជឿបានថា សូម្បីពួកគេមានអ៊ីម៉ែលក៏ដោយ ពួកគេកម្រប្រើប្រាស់អ៊ីម៉ែលណាស់) យើងត្រូវតែចាត់វិធានការដើម្បីធ្វើឲ្យប្រាកដថា អ្នកមានសិទ្ធិបោះឆ្នោតទាំងនោះពិតជាបានទទួលព័ត៌មានទាន់ពេលវេលា ដើម្បីពួកគេអាចពិចារណាសម្លេងឆ្នោតរបស់ខ្លួន។

នៅក្នុងករណីដែលការបោះឆ្នោតតាមប្រៃសណីយ៍ជាករណីចាំបាច់ ដើម្បីបញ្ចៀសការចោទប្រកាន់ទៅអនាគតអំពីការជ្រៀតជ្រែកពីរដ្ឋាភិបាល ការចែកចាយព័ត៌មានបែបនេះគួរតែប្រគល់ទៅឲ្យអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យណាមួយ – ដែលជាការសមស្របគួរតែជាអង្គការដែលមិនពាក់ព័ន្ធដោយផ្ទាល់នៅក្នុងកម្មវិធី REDD+ នៅកម្ពុជា – អង្គការ DPA អាចជាឧទាហរណ៍មួយ។